ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN
No : 011
Date: 11.01.12 Time: 11:00
For : GMAC

សាលារាជធានីភ្នំពេញ
លេខ: ១៩៨ សសរ.ចសច

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារចម្រុះត្រួតពិនិត្យ ទប់ស្កាត់ បង្ការគ្រោះអគ្គិភ័យជាយថាហេតុ នៅបណ្ដារោងចក្រ សហគ្រាស ឃ្លាំងស្តុកទំនិញ ស្ថានីយ៍ប្រេងឥន្ធនៈ សិប្បកម្ម ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

## អភិបាលរាជធានីភ្នំពេញ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៥៥ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ។

-យោងចំណុច ៤.១ នៃលិខិតលេខ ៤៧២ សជណ.សរ ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

-យោងសេចក្តីណែនាំលេខ ០០៣ សណន ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ។

-យោងសេចក្តីណែនាំលេខ ០៦ សណន.ស ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ របស់សាលាក្រុងភ្នំពេញ ។

-យោងតាមការចាំបាច់ចំពោះមុខ ។

## សម្រេច

**ប្រការ ១** .- បង្កើតក្រុមការងារចម្រុះចុះសហការពិនិត្យ ទប់ស្កាត់ បង្ការគ្រោះអគ្គិភ័យជាយថាហេតុនៅបណ្ដារោងចក្រ សហគ្រាស ឃ្លាំងស្តុកទំនិញ ស្ថានីយ៍ប្រេងឥន្ធនៈ សិប្បកម្ម ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. លោក | ប៉ា សុជាតិវង្ស | អភិបាលរងរាជធានីភ្នំពេញ | ប្រធាន |
| ២.លោក | ទូច ណារ៉ុថ | ស្នងការនគរបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៣.លោក | លី សាវេត | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | អនុប្រធាន |
| ៤.លោក | កើត ឆៃ | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៥.លោក | សុន សេងហួត | ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលរាជធានីភ្នំពេញ | សមាជិក |
| ៦.លោកអភិបាលខណ្ឌទាំង៩ | | | សមាជិក |
| ៧.លោក | នេត្រ វណ្ណា | នាយការិ.បង្ការ.ពន្លត់អគ្គិភ័យនៃស្នងការដ្ឋាននគរបាល | សមាជិក |

៨.លោកស្រី គឹម សេដ្ឋានី នាយិកាទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស សមាជិក

៩.លោក សែស សុខកុសល នាយករងទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស សមាជិក

១០.លោក កាំង លាងគ្រី ប្រធានការិយាល័យសុវត្ថិភាពសាធារណៈ សមាជិក

**ប្រការ ២** .-ក្រុមការងារមានភារកិច្ចដូចខាងក្រោម៖

-ត្រួតពិនិត្យប្រព័ន្ធបង្ការអគ្គិភ័យរបស់ រោងចក្រ សហគ្រាស ឃ្លាំងស្តុកទំនិញ ស្ថានីយ៍លក់ប្រេងឥន្ធនៈ សិប្បកម្មនីមួយៗ និងបណ្តាវិធានការដោះស្រាយ សង្គ្រោះពេលមានហេតុការណ៍អគ្គិភ័យកើតឡើង។

-ផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ពិសេសជំពូកទី៣ ( មាត្រា២៦ ២៧ ២៨ ២៩ និងមាត្រា៣០ ) ជំពូកទី៦ (មាត្រា៤៦) និងផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រង ដោះស្រាយគ្រោះអគ្គិភ័យ និងមាត្រា៤១៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-រៀបចំចងក្រង និងកសាងផែនការសកម្មភាពការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវដោយផ្អែកលើចំនួនទីតាំង គោលដៅ ភូមិសាស្ត្រ និងតំបន់ " ស ប្រផេះ ខ្មៅ " នៃកំរិតងាយឆាបឆេះ និងទំហំនៃគ្រោះមហន្តរាយប្រសិនបើមានកើតឡើង ។

**ប្រការ ៣** .-សមាជិកក្រុមការងារចម្រុះនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានតាមការចាំបាច់ ។

**ប្រការ ៤** .-នាយករដ្ឋបាលសាលារាជធានីភ្នំពេញ លោកស្នងការនគរបាលរាជធានីភ្នំពេញ លោកមេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ លោកប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលរាជធានីភ្នំពេញ គណៈអភិបាលខណ្ឌទាំង ៩ ក្នុងរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អភិបាលរាជធានីភ្នំពេញ**

**និងជាប្រធានគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ**

**កែប ជុតិមា**

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-អគ្គស្នងការដ្ឋាននគរបាលជាតិ

-ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

-មន្ទីរឧស្សាហកម្មរ៉ែ និងថាមពលរាជធានីភ្នំពេញ

-សាលាខណ្ឌទាំង៩

-សមាគមរោងចក្រកាត់ដេរកម្ពុជា

-សាមីខ្លួនដូចក្នុងប្រការ ១

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ